CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០២០

ទំនាក់ទំនង: Jane Grobaty, មន្ត្រីព័ត៌មានសហាគមន៍, មន្ទីរសួនឧទ្យាន, កំសាន្ត និងសមុទ្រ,
Jane.Grobaty@longbeach.gov

# សួនឧទ្យាន, កំសាន្ត និងសមុទ្រ ផ្តល់ជូនកម្មវិធីយុវជនរដូវក្តៅបន្ថែម

## *ជំរុំរដូវក្តៅនិម្មិត, ជំរុំធម្មជាតិមនុស្សផ្ទាល់ និងជំរុំសាលាអនុវិទ្យាល័យបន្សាំ*

## *ចាប់ផ្តើម នៅថ្ងៃទី ២០ ខែកក្កដា*

ដោយសារតែតម្រូវការសម្រាប់ការបង្កើនឱកាសរដូវក្តៅប្រកបដោយសុវត្ថិភាព, និងតម្រូវការសម្រាប់កម្មវិធីបន្ថែមនានា ដែលបានធ្វើការប្រកាសអោយបិទនាពេលថ្មីៗនេះ ដោយអភិបាលរដ្ឋ, នាយកដ្ឋានសួនឧទ្យាន, កំសាន្ត និងសមុទ្រ (PRM) បានដាក់បញ្ចូលកម្មវិធីបន្ថែមយ៉ាងបន្ទាន់, រួមទាំង ជំរុំមួយសំរាប់ ប្រជាជនដែលមានតម្រូវការពិសេស។ ចាប់ផ្តើមពីថ្ងៃច័ន្ទ ទី ២០ ខែកក្កដា, កម្មវិធី "ការកំសាន្តដែលបានស្រមៃឡើងវិញ" របស់ PRM នឹងត្រូវបានពង្រីកបន្ថែមទៀត ដើម្បីរួមបញ្ចូលនូវជំរុំនិម្មិតរដូវក្តៅ សម្រាប់កុមារអាយុ ៥ ឆ្នាំ ទៅដល់ ១២ ឆ្នាំ, ជំរុំដោយមនុស្សផ្ទាល់ នៅមជ្ឈមណ្ឌលធម្មជាតិ El Dorado សម្រាប់កុមារអាយុ ៥ ឆ្នាំ ទៅដល់ ៨ ឆ្នាំ និង ជំរុំដោយមនុស្សផ្ទាល់ ARISE (ការកំសាន្តបន្សាំក្នុងបរិដ្ឋានពិសេស) សំរាប់កុមារសិស្សសាលា ដែលមានវ័យកណ្តាល។

### ជំរុំរដូវក្តៅនិម្មិត

ដើម្បីផ្តល់ជូននូវជម្រើសសុវត្ថិភាពមួយផ្សេងទៀត សម្រាប់ការអប់រំ និងការកំសាន្ត ដែលមានការត្រូវការជាចាំបាច់, បុគ្គលិក PRM បានរៀបចំជំរុំនិម្មិតមួយ ជាមួយនឹងបទពិសោធន៍ជាច្រើន ដែលត្រូវបានផ្តល់ជូននៅជំរុំដោយមនុស្សផ្ទាល់របស់ PRM រួមជាមួយសកម្មភាពផ្សេងៗ នានាដើម្បីបង្កើនការសិក្សាដែលត្រូវបានរចនាឡើង ដើម្បីកាត់បន្ថយការបាត់បង់ការសិក្សា នៅរដូវក្តៅ។

ជំរុំនិម្មិតឥតគិតថ្លៃនានា នឹងរួមបញ្ចូលនូវពេលវេលាជួបផ្ទាល់ជាមួយបុគ្គលិកកំសាន្ត, ការរាំ, សិល្បៈ, រឿងនិទានរឿង និងអ្វីៗជាច្រើនទៀត ក្នុងរយៈពេលប្រាំមួយម៉ោងក្នុងមួយថ្ងៃៗ។ ជំរុំនិម្មិត នឹងត្រូវបានផ្តល់ជូន ដល់កុមារអាយុពី ៥ ឆ្នាំ ទៅដល់ ១២ ឆ្នាំ, ចាប់ពីម៉ោង ១០ ព្រឹក

ដល់ម៉ោង ៤ ល្ងាច នៅថ្ងៃធ្វើការ, ថ្ងៃទី ២០ ខែកក្កដា រហូតដល់ថ្ងៃទី ២៨ ខែសីហា។ ការចុះឈ្មោះមាន នៅគេហទំព័រ lbparks.org។

## ជំរុំរដូវក្តៅធម្មជាតិ El Dorado

កុមារដែលមានអាយុពីប្រាំឆ្នាំ ទៅប្រាំបីឆ្នាំ អាចចូលរួមជាមួយអ្នកធម្មជាតិ នៃ PRM នៅមជ្ឈមណ្ឌលធម្មជាតិ ដើម្បីភាពសប្បាយរីករាយ និងការរុករក, រួមទាំងសកម្មភាពនានាដោយផ្ទាល់, ល្បែងនានា និងសិប្បកម្មនានា។ វគ្គគឺចាប់ពីម៉ោង ១០ ព្រឹក ដល់ថ្ងៃត្រង់, នៅថ្ងៃធ្វើការ, ដោយ ថ្លៃចុះឈ្មោះ ៣០ ដុល្លារ ក្នុងមួយសប្តាហ៍។ ថ្ងៃកំណើតរបស់អ្នកបោះជំរុំ ត្រូវតែមុនថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៤។ មានការត្រួតពិនិត្យប្រចាំថ្ងៃជាចាំបាច់ នៅចន្លោះ ពីម៉ោង ៩:៣០ ដល់ ៩:៤៥ នាទី សម្រាប់ការពិនិត្យចូល និងត្រួតពិនិត្យសុខភាព។ រៀងរាល់សប្តាហ៍ មានប្រធានបទផ្សេងៗគ្នា។

- ព្រៃអំពីសិល្បៈ – ថ្ងៃទី ២០-២៤ ខែកក្កដា (Wild About Art – July 20-24)

  កុមារនឹងបង្កើតស្នាដៃសិល្បៈ ដែលត្រូវបានបំផុសគំនិតដោយពណ៌ និងវាយនភាពរបស់ធម្មជាតិ។ ថ្នាក់លេខ ៤០៩៩១។

- អ្វីគ្រប់យ៉ាងបក្សី – ថ្ងៃទី ២៧-៣១ ខែកក្កដា (Everything Birds – July 27-31)

  ស្វែងយល់ពីជម្រក ឬលំនៅដ្ឋាន, វដ្តជីវិត និងការសម្របខ្លួនរបស់បក្សី។ ថ្នាក់លេខ ៤០៩៩៣។

- NC អ្នកលេងល្បែង – ថ្ងៃទី ៣-៧ ខែសីហា (NC Gamers – August 3-7)

  ដកចេញ និងសាងសង់ និងលេងល្បែងដែលបំផុសគំនិតតាមបែបធម្មជាតិ ដោយប្រើគំនិតធម្មជាតិព្រៃរបស់យើង។ ថ្នាក់លេខ ៤០៩៩៤។

- អ្វីគ្រប់យ៉ាងអណ្តើក – ថ្ងៃទី ១០-១៤ ខែសីហា (Everything Turtles – August 10-14)

  ស្វែងយល់ពីពិភពអណ្តើកតាមរយៈជម្រក ឬលំនៅដ្ឋាន, វដ្តជីវិត និងការសម្របខ្លួន។ ថ្នាក់លេខ ៤០៩៩៥។

## ជំរុំសាលាអនុវិទ្យាល័យ ARISE (បន្សាំ)

PRM នឹងផ្តល់ជូនជំរុំរដូវក្តៅសម្រាប់អ្នកចូលរួម ARISE សំរាប់សិស្សសាលាដែលមានវ័យកណ្តាល (ការ កំសាន្តបន្សាំក្នុងបរិដ្ឋានពិសេស) ជាមួយនឹងសកម្មភាពកំសាន្ត និងបង្កើនចំណេះដឹង។ ជំរុំនឹងចាប់ផ្តើម ពីពេលថ្ងៃត្រង់ រហូតដល់ម៉ោង ៣ រសៀល នៅថ្ងៃធ្វើការ, ថ្ងៃទី ២០ ខែកក្កដា ដល់ថ្ងៃទី ២៨ ខែសីហា, នៅឯការិយាល័យតស៊ូមតិដើម្បីការគោរព & ជំរើស Advocacy for Respect & Choice (AR&C), 4519 E. Stearns Avenue។ ថ្លៃសេវា គឺ ១៥ ដុល្លារ ក្នុងមួយ សប្តាហ៍។ ជំរុំនឹងអនុវត្តតាមពិធីការសុវត្ថិភាពជំរុំពេលថ្ងៃ ហើយនឹងផ្តល់ជូននូវសមាមាត្រ បុគ្គលិកចំនួន ១:៥ នាក់នៃអ្នកបោះជំរុំ។ ការចុះឈ្មោះនឹងត្រូវបានធ្វើឡើង នៅនឹងកន្លែង AR&C។ អ្នកដែលមានចំណាប់អារម្មណ៍ អាចទូរស័ព្ទមកលេខ ៥៦២.៤៤០.២៨៦៧ សម្រាប់ព័ត៌មានបន្ថែម។

## ពិធីការសុវត្ថិភាពសម្រាប់ជំរុំធម្មជាតិ និង ARISE, ក៏ដូចជាជំរុំរដូវក្តៅ PRM ដោយមនុស្សផ្ទាល់, រួមមាន:

- កំណត់ចំនួនអ្នកចូលរួមនៅក្នុងជំរុំក្នុងមួយថ្ងៃៗ
- ចាត់តាំងអ្នកបោះជំរុំជាក្រុម ដែលមិនមានអន្តរ:កម្មរវាងក្រុមនៅជំរុំ
- រក្សាសមាមាត្រមិនឱ្យលើសពី ១២:១ សមាមាត្រទៅនឹងបុគ្គលិក - បុគ្គលិកដែលសមស្របទៅនឹងទំហំមជ្ឈមណ្ឌលសហគមន៍ (៥:១ សម្រាប់ ARISE)
- អនុវត្តពិធីការឃ្លាតឆ្ងាយរវាងកាយពីគ្នា រួមទាំងក្នុងកំឡុងពេលពិនិត្យចូល និងពិនិត្យចេញ
- ការសំអាត និងការធ្វើអនាម័យសម្ភារ:ជាច្រើនដង ក្នុងមួយថ្ងៃៗ
- ការសំអាត និងការធ្វើអនាម័យ នៅរាល់តំបន់ដែលមានប៉ះពាល់ខ្ពស់អោយបានញឹកញាប់
- តម្រូវអោយមានការបិទបាំងមុខ សំរាប់អ្នកចូលរួម និងបុគ្គលិក

សម្រាប់ព័ត៌មានថ្មីៗចុងក្រោយ ស្តីពីជំងឺ COVID-19, ដែលលំអិតអំពីអ្វីៗទាំងអស់ ដែលទីក្រុងឡុងប៊ីចកំពុងធ្វើ ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនរបស់យើង, ទស្សនា: longbeach.gov/COVID19 និងតាមមើល @LongBeachCity នៅលើ Facebook, Twitter និង Instagram.

###